# តារាងស្តីពីព័ត៌មានរបស់គម្រោង

លេខPIP : 928

(សម្រាប់បំពេញដោយក្រសួងផែនការ)

## ព័ត៌មានមូលដ្ឋានអំពីគម្រោង

ផ្នែក ក

*(ត្រូវបំពេញគ្រប់ចំណុចទាំងអស់)*

១. ឈ្មោះគម្រោង : យន្តការតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្ត និងយន្តការដោះស្រាយវិវាទក្នុង វិស័យសាធារណការ និងដឹកជញ្ជូន

២. កាលបរិច្ឆេទគម្រោង

កាលបរិច្ឆេទចាប់ផ្តើមគម្រោង 01/01/20

កាលបរិច្ឆេទបញ្ចប់គម្រោង 31/12/22

៣. ចំណាយគម្រោងសរុប $1,090,000

៤. ស្ថាប័នទទួលខុសត្រូវ ក្រសួងសាធារណការ និងដឹកជញ្ជូន

RESPONSIBLE UNIT General Department of Administration and Finance

អង្គភាពទទួលខុសត្រូវ អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ

៥. ស្ថានភាពគម្រោង គម្រោងដែលបានលុបចោល

ព័ត៌មានលម្អិតអំពីគម្រោង

៦. ប្រភេទគម្រោង ៖ គម្រោងជំនួយបច្ចេកទេស

៧. ប្រភពហិរញ្ញប្បទាន៖ ស្វែងរកម្ចាស់ជំនួយ

៨. មុំនៃគោលនយោបាយក្នុងយុទ្ធសាស្រ្តបញ្ចកោណ ដំណាក់កាលទី១ ដែលគម្រោងស្ថិតនៅ

មុំទី១- ការពង្រឹង និងការកែទម្រង់ស្ថាប័ន

៩. ការចូលរួមចំណែករបស់គម្រោងក្នុងការសម្រេចបានគោលនយោបាយអាទិភាពខាងលើ

គម្រោងនេះនឹងអាចធ្វើឱ្យមន្រ្តីជំនាញសាធារណៈ មានសមត្ថភាពក្នុងការពិនិត្យ និងវាយតម្លៃច្បាប់ និងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗក្នុងវិស័យសារណការនិងដឹកជញ្ជូន និងដើម្បីឱ្យមន្រ្តីជំនាញពាក់ព័ន្ធផ្តល់នូវការរួម ចំណែកណែនាំ យ៉ាងមានប្រសិទ្ធភាពនិងទាន់ពេលវេលា ដល់ការអនុវត្តច្បាប់និងបទបញ្ញត្តិផ្សេងៗ ក៏ដូចជាការចូល រួមកែលម្អនិងអភិវឌ្ឍលិខិតបទដ្ឋានគតិយុត្តទាំងនោះ។ លើសពីនេះ យន្តការនេះនឹងរួមចំណែកក្នុងការដោះស្រាយវិវាទដឹកជញ្ជូន វិវាទកិច្ចសន្យា និងវិវាទលើបញ្ញត្តិផ្សេងៗ ដែលកើតមានឡើងនៅក្នុងវិស័យសាធារណការ និងដឹកជញ្ជូន។ នៅក្នុងន័យនេះ យន្តការនេះមិនត្រឹមត្រូវបានផ្តល់នូវ វិធានវិជ្ជជីវៈ ដ៏ជាក់លាក់មួយសម្រាប់ដោះស្រាយវិវាទនោះទេ វាក៏បានជួយកាត់បន្ថយនូវបន្ទុករបស់ប្រព័ន្ធតុលាការ ក្នុងប្រទេស តុលាការខេត្តក្រុង និងយន្តការតុលាការតាមតំបន់ ដែលកំពុងមានភាពមមាញឹកជាមួយករណីបណ្តឹង ជាច្រើន។

១០. ការគាំទ្រដល់គោលនយោបាយអភិវឌ្ឍន៍ វិស័យឧស្សាហកម្មកម្ពុជា

តើគម្រោងនេះគាំទ្រដល់ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាដែរឬទេ ? មិនគាំទ្រ

១១. វិស័យ ( សូមប្រើវិស័យ អនុវិស័យ ដែលមានចែងក្នុងផ.យ.អ.ជ. )

អភិបាលកិច្ច និងរដ្ឋបាល Governance and Administration

១២. ទីតាំងអនុវត្តគម្រោង ( ពិពណ៌នាពីទីតាំងដែលត្រូវអនុវត្តគម្រោង )

គ្រប់ខេត្តក្រុង,

១៣. គោលបំណងរបស់គម្រោង ( ពិពណ៌នាគោលបំណងចម្បងៗរបស់គម្រោង )

- រៀបចំនូវយន្តការនិងសូចនាករសម្រាប់ធ្វើការផ្ទៀងផ្ទាត់ និងវាយតម្លៃនូវប្រសិទ្ធភាពនៃការអនុវត្តច្បាប់
- សិក្សានិងវាយតម្លៃនូវប្រព័ន្ធច្បាប់ក្នុងវិស័យសាធារណការនិងដឹកជញ្ជូន
- ធ្វើឱ្យសេដ្ឋកិច្ចជាតិរីកចម្រើន នៅពេលដែលមានការអនុវត្តច្បាប់និងលិខិតបទដ្ឋាន យ៉ាងមានប្រសិទ្ធភាព
- ដាក់ចេញនូវគោលការណ៍វាយតម្លៃអភិបាលកិច្ចនិយតកម្ម
- ធ្វើវិសោធនកម្មលិខិតបទដ្ឋានគតិយុត្ត បើចាំបាច់
- ពង្រឹងគោលនយោបាយបទបញ្ញត្តិនិងការអនុវត្ត ក្នុងវិស័យសាធារណការនិងដឹកជញ្ជូន
- ទទួលបាននូវវិជ្ជាជីវៈជំនាញផ្លូវការក្នុងដោះស្រាយវិវាទក្នុងវិស័យសាធារណការនិងដឹកជញ្ជូន
- ដើម្បីទទួលបានយន្តការយ៉ាងពិតប្រាកដមួយសម្រាប់មន្ត្រីជំនាញអនុវត្ត
- ដើម្បីធានាថា ទាំងលទ្ធផលនិងប្រសិទ្ធផលគឺអាចទទួលយកបានពីភាគីពាក់ព័ន្ធទាំងអស់
- រួមចំណែកក្នុងការកាត់បន្ថយបន្ទុកប្រព័ន្ធយុត្តិធិការក្នុងប្រទេស
- ផ្តល់ជម្រើសល្អមុនឈានដល់ការប្រើប្រាស់ប្រព័ន្ធយុត្តិធិការក្នុងប្រទេស
- ពង្រឹងការធ្វើបញ្ញត្តិកម្មក្នុងវិស័យសាធារណការនិងដឹកជញ្ជូន។

១៤. ការពិពណ៌នាអំពីគម្រោង ( ពិពណ៌នាអំពីសមាសភាគទាំងអស់របស់គម្រោង )

គម្រោងការវាយតម្លៃផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្តក្នុងវិស័យសាធារណការនិងដឹកជញ្ជូនមានដំណាក់កាលធំៗ ៣គឺ៖- ការចរចា

- ការសម្របសម្រួល
- សន្និដ្ឋាននិងការវិនិច្ឆ័យដោយផ្អែកលើបទបញ្ញត្តិ

យន្តការនេះរួមមានសមាសធាតុសំខាន់ៗ ៨ ចំណុច រួមមាន៖

- រៀបចំយន្តការដោយផ្អែកលើច្បាប់ក្នុងប្រទេស
- ការកំណត់បញ្ហា
- កំណត់គោលបំណង
- វាយតម្លៃផលប៉ះពាល់ភាគីនីមួយៗ
- ផ្តល់យោបល់ ឬចរចា
- ត្រួតពិនិត្យនិងវាយតម្លៃ
- សម្របសម្រួល
- សន្និដ្ឋាននិងការវិនិច្ឆ័យដោយផ្អែកលើបទបញ្ញត្តិ។

១៥. យុត្តិកម្មលើគម្រោង ( បង្ហាញពីហេតុផលថាហេតុអ្វីបានជាគម្រោងនេះត្រូវបានជ្រើសរើស )

ហូតមកដល់ពេលនេះនៅមិនទាន់មានយន្តការណាមួយសម្រាប់ពិនិត្យវាយតម្លៃច្បាប់និងការអនុវត្តនូវលិខិតបទដ្ឋាន គតិយុត្ត និងសម្រាប់ដោះស្រាយវិវាទក្នុងវិស័យសាធារណការនិងដឹកជញ្ជូន ដែលកំពុងដើរតួនាទីយ៉ាងសំខាន់ក្នុងការ អភិវឌ្ឍសេដ្ឋកិច្ចជាតិ។ ការអនុវត្តច្រមានប្រសិទ្ធភាពនូវការត្រួតពិនិត្យវាយតម្លៃ និងដោះស្រាយវិវាទក្នុងវិស័យសាធារ ណការនិងដឹកជញ្ជូន តម្រូវឱ្យមាននូវយន្តការនិងស្ថាប័នជំនាញមួយ ដែលអាចជួយជាគោលការណ៍ណែនាំ។

ដូច្នេះគម្រោងនេះនឹងបានផ្តល់នូវប្រយោជន៍ ជាច្រើនដូចជា៖

- កែលម្អកំណែទម្រង់ច្បាប់និងការអនុវត្តច្បាប់ក្នុងវិស័យការងារសាធារណការនិងដឹកជញ្ជូន
- បង្កើនប្រសិទ្ធភាពនិងប្រសិទ្ធផលនៃការអនុវត្តច្បាប់និងបទប្បញ្ញត្តិ
- ធានានូវតម្លាភាពនិងឥតខ្ចោះនៃការអនុវត្តច្បាប់និងបទប្បញ្ញត្តិ
- ជួយសម្រេចបាននូវគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មឆ្នាំ 2015-2025 តាមរយៈការធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធ ច្បាប់ក្នុងវិស័យសាធារណៈនិងការដឹកជញ្ជូន
- ទទួលបាននូវយន្តការមួយសម្រាប់នីតិវិធីដោះស្រាយវិវាទក្នុងវិស័យសាធារណការនិងដឹកជញ្ជូន
- ទទួលបាននូវលទ្ធផល និងប្រសិទ្ធផលមួយដែលអាចទទួលយកបានសម្រាប់ភាគីជម្លោះ
- ពង្រឹងប្រព័ន្ធយន្តការការងារសម្រាប់ការដោះស្រាយវិវាទ
- កាត់បន្ថយនូវបន្ទុកការងាររបស់ប្រព័ន្ធតុលាការជាតិ

**១៦. ផលប្រយោជន៍របស់គម្រោង** (រៀបរាប់ពីអ្នកដែលនឹងទទួលប្រយោជន៍ផ្ទាល់និងមិនផ្ទាល់ពីការអនុវត្តគម្រោង)

អ្នកដែលនឹងទទួលប្រយោជន៍ផ្ទាល់និងមិនផ្ទាល់ពីការអនុវត្តគម្រោងមានដូចតទៅ៖

- ប្រទេសកម្ពុជាទាំងមូល
- ប្រជាជនកម្ពុជាទូទាំងប្រទេស
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ប្រទេសដែលជាម្ចាស់ជំនួយនិងដៃគូអភិវឌ្ឍនានា។

**១៧. ការសិក្សាសមិទ្ធិលទ្ធភាព**

តើគម្រោងនេះតម្រូវឲ្យមានការសិក្សាសមិទ្ធិលទ្ធភាពដែរ ឬទេ? **មាន**

ប្រសិនបើត្រូវការ តើការសិក្សាសមិទ្ធិលទ្ធភាព បានរៀបចំហើយឬនៅ? **មិនទាន់ចាប់ផ្តើម**

**១៨. ផលប៉ះពាល់ផ្នែកបរិស្ថាននិងសង្គម** (ពិពណ៌សង្ខេបពីផលប៉ះពាល់របស់គម្រោងលើប្រជាជននិងបរិស្ថានជុំវិញ ប្រសិនបើមាន។ តើគម្រោងនេះនឹងជួយដល់ការកាត់បន្ថយភាពក្រីក្រដែរឬទេ?)

គម្រោងនេះមិនមានផលប៉ះពាល់ដល់ប្រជាជននិងបរិស្ថានជុំវិញទេ ពីព្រោះគោលបំណងចម្បងនៃគម្រោងនេះគឺ កាត់បន្ថយផលប៉ះពាល់លើគ្រប់វិស័យតាមលទ្ធភាពដែលអាចធ្វើបាន។

**១៩. ការប្រែប្រួល អាកាសធាតុ**

ក. តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ ទងនឹងការប្រែប្រួលអាកាសធាតុ ឬទេ? **គ្មាន**

ខ. តើគម្រោងមានភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុកម្រិតណា?

សូមជ្រើសរើសវិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងនិងបំពេញការចូលរួមចំណែកនៃចំណាយដែល ទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងធៀបនឹងតម្លៃគម្រោងសរុប។

| វិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ | ភាគរយ | ភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុ |
|---|---|---|

**២០. ការកាត់បន្ថយ ហានិភ័យ និង គ្រោះមហន្តរាយ**

តើសកម្មភាព ឬជាតុចេញរបស់គម្រោងទាក់ទងនឹងការកាត់បន្ថយហានិភ័យ និងគ្រោះមហន្តរាយដែរឬទេ? **គ្មាន**

**២១. ការវិភាគយេនឌ័រ** (តើគម្រោងនេះមានផលប៉ះពាល់ដល់តួនាទីរបស់បុរសនិងស្ត្រីក្នុងទីតាំងរបស់គម្រោងនេះដូចម្តេច? តើស្ត្រីនឹងត្រូវចូលរួមយ៉ាងសកម្មក្នុងការអនុវត្តគម្រោងនេះដែរឬទេ?)

គម្រោងនេះមិនមានផលប៉ះពាល់ដល់តួនាទីរបស់បុរសនិងស្ត្រីក្នុងទីតាំងរបស់គម្រោងនេះ។ ផ្ទុយទៅវិញ គម្រោងនេះនឹងចូលរួមលើកកម្ពស់សមភាពយេនឌ័រនៅ ក្នុងការចូលរួមសិក្សា វិភាគ និងចូលរួមយោបល់ និង/ឬចូលរួមសកម្មភាពជាច្រើនតាមដែលអាចធ្វើបាន។

**២២. សមត្ថភាពអនុវត្តគម្រោង** (តើក្រសួងមានជំនាញនិងបទពិសោធន៍គ្រប់គ្រាន់សម្រាប់អនុវត្តគម្រោងដែរឬទេ?)

ក្រសួងមានមន្ត្រីជំនាញ ដែលមានសមត្ថភាពនិងបទពិសោធន៍ពេញលេញ និងគ្រប់គ្រាន់ដើម្បីអនុវត្តគម្រោងនេះ។ ជំនាញដែលមានដើម្បីអនុវត្តគម្រោងនេះរួមមាន ច្បាប់ ស្រាវជ្រាវនិងអភិវឌ្ឍន៍ ភាសាអង់គ្លេស វិទ្យាសាស្ត្រកុំព្យូទ័រ សេដ្ឋកិច្ច និងទំនាក់ទំនងអន្តរជាតិ។ ប៉ុន្តែក្រសួងក៏ត្រូវការការបណ្តុះបណ្តាលបន្ថែមអ្នកបច្ចេកទេស និងជំនួយពីដៃ គូអភិវឌ្ឍន៍ដើម្បីសហការ និង[illegible]

**២៣. ដំណើរការនៃការអនុវត្តគម្រោង** (ពិពណ៌[illegible]គម្រោងនិងបង្ហាញអំពីភាពប្រឈមនានា ដែល បណ្តាលឲ្យមាន ការព្យាពេលក្នុងការអនុវត្តគម្រោង។)

គម្រោងនេះនឹងដំណើរការតាមការគ្រោងទុកបើសិនជាមានថវិកាគ្រប់គ្រាន់សម្រាប់ការអនុវត្តគម្រោង។

**២៤. អាទិភាពរបស់គម្រោង** (បញ្ជាក់ពីការកំណត់អាទិភាពរបស់គម្រោងរបស់ក្រសួង ស្ថាប័ន)

10

**២៥. ការចូលរួមរបស់ដៃគូអភិវឌ្ឍ** (ផ្តល់ព័ត៌មានអំពីដៃគូអភិវឌ្ឍសក្តានុពល ដែលពាក់ព័ន្ធនឹងគម្រោងនេះ)

- សាធារណរដ្ឋប្រជាមានិតចិន
- កូរ៉េ
- ជប៉ុន
- ធនាគារអភិវឌ្ឍអាស៊ី
- ធនាគារពិភពលោក
- អង្គការ និងដៃគូអភិវឌ្ឍន៍នានា។

## ផ្នែក ខ ចំណាយរបស់គម្រោងនិងប្រភពហិរញ្ញប្បទាន

*(គិតជាពាន់ដុល្លារអាមេរិក)*

| ចំណាយវិនិយោគ | 2021 | | 2022 | 2023 | 2024 | 2025 | សរុប | ថវិកា |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2023-2025 | ចរន្ត |
| **ចំណាយប្រតិបត្តិ** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| បៀវត្សរ៍ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| សម្ភារៈនិងរដ្ឋបាល | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| **ចំណាយមូលធន** | 0.0 | 0.0 | 0.0 | 355.0 | 355.0 | 380.0 | 1,090.0 | 0.0 |
| | | | | | | | | |
| ការសាងសង់ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| សេវាទីប្រឹក្សា | 0.0 | 0.0 | 0.0 | 150.0 | 150.0 | 150.0 | 450.0 | 0.0 |
| ទព្វសម្ភារៈ | 0.0 | 0.0 | 0.0 | 100.0 | 100.0 | 100.0 | 300.0 | 0.0 |
| ការបណ្តុះបណ្តាល | 0.0 | 0.0 | 0.0 | 75.0 | 75.0 | 100.0 | 250.0 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 30.0 | 30.0 | 30.0 | 90.0 | 0.0 |
| | | | | | | | | |
| **ចំណាយសរុប** | 0.0 | 0.0 | 0.0 | 355.0 | 355.0 | 380.0 | 1,090.0 | 0.0 |
| | | | | | | | | |

| ប្រភពហិរញ្ញប្បទាន | 2021 | | 2022 | 2023 | 2024 | 2025 | សរុប | |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2023-2025 | |
| | | | | | | | | |
| ចំណូលពីគម្រោង | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| ថវិកាជាតិ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| សាច់ប្រាក់សុទ្ធ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| ធនធានផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| ហិរញ្ញប្បទាន របស់ ដៃគូអភិវឌ្ឍ | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| សរុបហិរញ្ញប្បទាន ដែលបានសន្យាផ្តល់ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| តម្រូវហិរញ្ញប្បទាន បំពេញបន្ថែម | 0.0 | 0.0 | 0.0 | 355.0 | 355.0 | 380.0 | 1,090.0 | |

**បានឃើញ និង ឯកភាព**

**រដ្ឋមន្ត្រី**

កាលបរិច្ឆេទ: